## ៤.២- ប្រកាសលេខ ៧៩៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងបុរេប្រទានគ្រប់ប្រភេទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...៧៩៩...សហវ-ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៨

## ប្រកាស

## ស្តីពី

## ការបង្កើតក្រុមការងារគ្រប់គ្រងប្រាក់បុរេប្រទានគ្រប់ប្រភេទ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ។

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៩ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខនស/រកម/១២០២/០២០ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ។

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សំរេច

**ប្រការ១:** ត្រូវបានបង្កើតឡើងនូវក្រុមការងារគ្រប់គ្រងប្រាក់បុរេប្រទានគ្រប់ប្រភេទ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១. លោក | **ឡូច ខ្មៅ** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច | ប្រធាន |
| ២ .លោក | **លី សែ** | អនុប្រធានទី១នាយកដ្ឋានអាសាន | អនុប្រធាន |
| ៣ .លោក | **ម៉ែន ធីរុន្ធ** | អនុប្រធាននាយកដ្ឋានវិនិយោគក្នុងស្រុកទី១ | អនុប្រធាន |
| ៤ .លោក | **ឈាន ហៀង** | អនុប្រធាននាយកដ្ឋានរតនាគារជាតិ | អនុប្រធាន |
| ៥ .លោក | **អ៊ុន សុម៉េធ** | ប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ | លេខាអចិន្ត្រៃយ៍ |
| ៦ .លោក | **លី សំអុល** | ប្រធានការិយាល័យហិរញ្ញកិច្ចទី១ | សមាជិក |
| ៧ .លោកស្រីកែវ | **ផល្លី** | អនុប្រធានការិយាល័យថវិកា | សមាជិក |
| ៧ .លោក | **សួន ទិចិត្រ** | អនុប្រធានអង្គភាពគ្រប់គ្រងសាច់ប្រាក់ | សមាជិក |
| ៨ .លោក | **សុខ ពេជ្រនិល** | មន្ត្រីទទួលបន្ទុកបុរេប្រទានរតនាគារជាតិ | សមាជិក |
| ៩ .លោក | **អាង ណារ៉ា** | មន្ត្រីទទួលបន្ទុកបុរេប្រទានរូបិយប័ណ្ណរតនាគារជាតិ | សមាជិក |
| ១០ .លោក | **តែ យូរ៉ន** | មន្ត្រីទទួលបន្ទុកបុរេប្រទានចរន្តរតនាគារជាតិ | សមាជិក |
| ១១.លោក | **អ៊ុក ចន្ទរដ្ឋា** | មន្ត្រីទទួលបន្ទុកបុរេប្រទានវិនិយោគរតនាគារជាតិ | សមាជិក |

**ប្រការ២:** ក្រុមការងារគ្រប់គ្រងប្រាក់បុរេប្រទានគ្រប់ប្រភេទ មានភារៈកិច្ច:

១-ត្រួតពិនិត្យ និងកំណត់ការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ននីមួយៗ និងភាពចាំបាច់នៃប្រាក់បុរេប្រទាន

២-បង្កើនសមត្ថភាព និងបណ្ដុះបណ្ដាលមន្ត្រីនានារបស់ក្រសួង-ស្ថាប័ន ដែលប្រើប្រាស់ និងអនុវត្តប្រាក់បុរេប្រទាន

៣-ចាប់ពីចុងត្រីមាសទី៣ នៃឆ្នាំ ត្រូវពិនិត្យជាទូទៅអំពីការជំរះទូទាត់ប្រាក់បុរេប្រទាន ជៀសវាងការលើកទៅឆ្នាំបន្ទាប់

៤-ពិនិត្យលើការស្នើសុំ ឥណទានបន្ថែមសំរាប់បុរេប្រទាន តាមបណ្ដាក្រសួង-ស្ថាប័ននីមួយៗ ក្នុងការិយបរិច្ឆេទគណនេយ្យ និងថវិកាប្រចាំឆ្នាំ ។

**ប្រការ៣:** ឯកឧត្ដម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់សហការជាមួយក្រុមការងារខាងលើ អនុវត្តអោយបានហ្មឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់បំផុត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន:**

- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ទីស្ដីការគណៈរដ្ឋមន្ត្រី
- -គ្រប់ក្រសួង-ស្ថាប័ន " ដើម្បីជូនជ្រាប "
- -ដូចប្រការ៣
- -ឯកសារ-កាលប្បវត្តិ